**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខ: ១៩៧៥ អក

ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១

សាលក្រមលេខ៖ ៨៤ (ណ)

ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្តាល

-បានបើកសវនាការជំនុំជម្រះសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ដោយមានសមាសភាពដូចតទៅ:

### សមាសភាពជំនុំជំរះ

| | | |
|---|---|---|
| លោក | [redacted] | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| លោកស្រី | | ចៅក្រមប្រឹក្សា |
| លោក | | ចៅក្រមប្រឹក្សា |

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

### មេធាវី

មេធាវី [redacted] មេធាវីការពារជនជាប់

**ដើម្បីជំនុំជំរះ** សំណុំរឿងព្រហ្មទណ្ឌលេខ: ១៩៧៥ អក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ធារ៉ា ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើត ស[redacted] រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្ននៅភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] វិបុល (រស់) ម្តាយឈ្មោះ[redacted] ផល្លា (រស់) នៅលីវ ជានីតិជន ទោសពីមុន៖ គ្មាន (**ឃុំខ្លួនថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១** )។

២-ឈ្មោះ [redacted] សុធី ហៅ អាញ៉ាញ់ ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរ ជាងទឹក ជាងភ្លើង ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សុធា (រស់) ម្តាយឈ្មោះ[redacted] សាប (រស់) នៅលីវ ជានីតិជន ទោសពីមុន៖ គ្មាន (**ឃុំខ្លួនថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១** )។

៣-ឈ្មោះ [redacted] ឈុននី ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើត នៅ[redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូមិព្រែកតាឡុង៣ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] គឹមទី (រស់) ម្តាយឈ្មោះ [redacted] សុជា (រស់) នៅលីវ ជាអនីតិជន ទោសពីមុនៈ គ្មាន (ឃុំខ្លួនថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ )។

៤-ឈ្មោះ [redacted] ប៉ូវ៉ា ភេទប្រុស អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតភូមិ និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ ស្វា (រស់) ម្តាយឈ្មោះ ចេក (រស់) នៅលីវ ជាអនីតិជន ទោសពីមុនៈ គ្មាន (ឃុំខ្លួនថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១)។

ត្រូវជាប់ចោទពីបទៈ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិដើមគរ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ បញ្ញត្តិផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខៈ ២២៤ ដកសព ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

**បានឃើញ** ដីកាដំណោះស្រាយលេខៈ ៣៤១ ដកដស ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកណ្តាល ។

**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ៣៧០ ដកចត ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទ

កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ២២ និង០០នាទី កម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលដើមមៀន បានចេញល្បាតមកដល់ចំណុចផ្លូវលំ ដែលស្ថិតនៅភូមិដើមគ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ក៏បានប្រទះឃើញជនសង្ស័យចំនួន ០៤នាក់ ឈ្មោះ [redacted] ធារ៉ា ភេទប្រុស អាយុ ២៥ឆ្នាំ ,ឈ្មោះ [redacted] សុធី ហៅ អាញ៉ាញ់ ភេទប្រុស អាយុ ២០ឆ្នាំ ,ឈ្មោះ [redacted] ឈុននី ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ [redacted] ប៉ូវ៉ា ភេទប្រុស អាយុ ១៧ឆ្នាំ កំពុងអង្គុយលេងនៅលើផ្លូវ ដោយមានការសង្ស័យ កម្លាំងសមត្ថកិច្ចក៏បានឃាត់សាកសួរនាំ និងបានឆែកឆេររកឃើញថ្នាំញៀនចំនួន ០២កញ្ចប់ ដោយរកឃើញនៅក្នុងហោប៉ៅខោខាងស្តាំរបស់ឈ្មោះ [redacted] ធារ៉ា ចំនួន ០១កញ្ចប់ និងនៅជាប់ខ្លួនរបស់ឈ្មោះ [redacted] សុធី ចំនួន ០១កញ្ចប់។ បន្ទាប់មកកម្លាំងសមត្ថកិច្ចក៏បានចាប់ខ្លួនជនសង្ស័យទាំងបួននាក់ខាងលើ និងវត្ថុតាងបញ្ជូនមកកាន់អធិការដ្ឋាននគរបាលក្រុងតាខ្មៅ ដើម្បីចាត់ការតាមនីតិវិធី។ ក្រោយឃាត់ខ្លួន សមត្ថកិច្ចក៏បានធ្វើតេស្តទឹកនោមលើជនសង្ស័យទាំង៤ នាក់ខាងលើ ហើយលទ្ធផលបានបញ្ជាក់ថា មានសារធាតុញៀននៅក្នុងទឹកនោមនោះផងដែរ។

## នាពេលសវនាការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានរបាយការណ៍របស់នគរបាលយុត្តិធម៌

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់។



Scanned with CamScanner

# សាលាដំបូងខេត្តកណ្តាល
## យល់ឃើញថា

**ក.អំពីពិរុទ្ធភាព៖**

១-តាមដីកាដំណោះស្រាយលេខ ៣៤១ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ភេទប្រុស អាយុ ២៥ឆ្នាំ ,ឈ្មោះ [redacted] សុធី ហៅ អាញ៉ាញ់ ភេទប្រុស អាយុ ២០ឆ្នាំ ,ឈ្មោះ [redacted] ឈុនន័ី ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ [redacted] បូរ៉ា ភេទប្រុស អាយុ ១៧ឆ្នាំ មកតុលាការដើម្បីជម្រះពីបទ៖ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិដើមគរ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ បញ្ញត្តិផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ធារ៉ា បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនបានទិញថ្នាំញៀនពីគេមិនស្គាល់ឈ្មោះចំនួន ០១កញ្ចប់តូច តម្លៃ ១៥,០០០រៀល ។ ក្រោយពីទិញថ្នាំញៀនបានហើយ ខ្លួនបានត្រឡប់ទៅធ្វើការវិញ លុះពេលចេញពីធ្វើការ ខ្លួនក៏បានត្រឡប់មកផ្ទះវិញ ហើយបានជួបឈ្មោះ [redacted] សុធី ,ឈ្មោះ [redacted] បូរ៉ា និងឈ្មោះ [redacted] ឈុននី ហើយខ្លួនក៏បានឈប់អង្គុយលេងជាមួយពួកគេ បានប្រហែល ១០នាទី ស្រាប់តែមានសមត្ថកិច្ចមកដល់ចាប់ពួកខ្លួនតែម្តង។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនរយៈពេល ០២ឆ្នាំមកហើយ តែមិនដែលយកថ្នាំញៀនទៅលក់ឱ្យគេទេ។

៣-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុធី បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនបានទិញថ្នាំញៀនពីគេមិនស្គាល់ឈ្មោះចំនួន ០១កញ្ចប់តូច តម្លៃ ១៥,០០០រៀល ។ ក្រោយពីទិញថ្នាំញៀនបានហើយខ្លួនក៏ត្រឡប់ទៅផ្ទះវិញ លុះដល់ម៉ោងប្រហែល ១០យប់ ខ្លួនក៏បានមកអង្គុយលេងជាមួយឈ្មោះ [redacted] បូរ៉ា និងឈ្មោះ [redacted] ឈុននី ស្រាប់តែឈ្មោះ [redacted] ធារ៉ា បានមកដល់ ហើយសមត្ថកិច្ចក៏បានមកតាមពីក្រោយ ហើយឃាត់ខ្លួនពួកខ្លួនតែម្តង។ ថ្នាំញៀនដែលខ្លួនទិញមកនេះគឺទុកសម្រាប់ប្រើប្រាស់ម្នាក់ឯងទេ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនរយៈពេល ០២ឆ្នាំមកហើយ តែមិនដែលយកថ្នាំញៀនទៅលក់ឱ្យគេទេ។

៤-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ឈុននី បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនបានអង្គុយលេងជាមួយឈ្មោះ ស្នា បូរ៉ា ដើម្បីរង់ចាំគេទៅដូរវង្វាន់ស្រាបៀរយកមកផឹក។ នៅពេលពួកខ្លួនកំពុងអង្គុយ ស្រាប់តែឈ្មោះ [redacted] សុធី និងឈ្មោះ [redacted] ធារ៉ា បានមកអង្គុយលេងជាមួយពួកខ្លួន បានប្រហែល ១០នាទី ស្រាប់តែសមត្ថកិច្ចបានមកដល់ចាប់ឃាត់ពួកខ្លួនតែម្តង។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនរយៈពេល ០២ខែមកហើយ តែមិនដែលយកថ្នាំញៀនទៅលក់ឱ្យគេទេ។

៥-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួនបានអង្គុយលេងជាមួយឈ្មោះ [redacted] ឈុននី ដើម្បីរង់ចាំគេទៅដូរវង្វាន់ស្រាបៀរយកមកផឹក។ នៅពេលពួកខ្លួនកំពុងអង្គុយ ស្រាប់តែឈ្មោះ [redacted] សុធី និងឈ្មោះ [redacted] ធារ៉ា បានមកអង្គុយលេងជាមួយពួកខ្លួន បានប្រហែល ១០នាទី ស្រាប់តែសមត្ថកិច្ចបានមកដល់ចាប់ឃាត់ពួកខ្លួនតែម្តង។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនរយៈពេល ០២ឆ្នាំមកហើយ ដោយប្រើឈប់ប្រើឈប់ តែមិនដែលយកថ្នាំញៀនទៅលក់ឱ្យគេទេ។

៦-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ៖ ក្រោយពីបានស្តាប់ការសួរដេញដោលក្នុងអង្គសវនាការួច កូនក្តីខ្ញុំបានទទួលស្គាល់តែក្នុងកម្រិតប្រើប្រាស់តែប៉ុណ្ណោះ ដោយមិនបានជួញដូរបន្តទេ។ ទង្វើដែលកូនក្តីខ្ញុំបាទបានធ្វើកន្លងមកដោយសារតែការសិក្សារបស់ពួកគាត់មានកម្រិត ខ្វះការពិចារណា ព្រមទាំងមានការអូសទាញពីមនុស្សដែលពួកគាត់រាប់អានជាដើម ម៉្យាងវិញទៀតកូនក្តីខ្ញុំទាំងពីរនាក់គឺជាអនីតិជនទៀតផង។ ហេតុដូច្នេះ ស្នើសុំ



Scanned with CamScanner

ដល់លោកប្រធានក្រុមប្រឹក្សាជំនុំជម្រះលុបបទចោទប្រកាន់ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ដោយកូនក្តីខ្ញុំមិនបានធ្វើការរក្សាទុកនោះទេ។

៧-តាមកំណត់ហេតុទទួលវត្ថុតាងបានបង្ហាញថា ម៉្សៅក្រាមសថ្លាដែលសង្ស័យជាសារធាតុញៀនប្រភេទម៉ាទឹកកក ត្រូវដកហូតពីជនជាប់ចោទសរុប មានទម្ងន់ ០,១៩ (សូន្យក្បៀសដប់ប្រាំបួន)ក្រាម ។

៨-តាមរបាយការណ៍របស់នគបាលយុត្តិធម៌បានបញ្ជាក់ថា៖ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ នៅភូមិដើមគ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ឈ្មោះ [redacted] ធារ៉ា ,ឈ្មោះ [redacted] សុធី ,ឈ្មោះ [redacted] ឈុននី និងឈ្មោះ [redacted] ប៉ូរ៉ា ពិតជាបានប្រព្រឹត្តបទល្មើស **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ពិតប្រាកដមែន ។

៩-តំណាងអយ្យការបានសន្និដ្ឋានថា៖ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ នៅភូមិដើមគ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ឈ្មោះ [redacted] ធារ៉ា ,ឈ្មោះ [redacted] សុធី ,ឈ្មោះ [redacted] ឈុននី និងឈ្មោះ [redacted] ប៉ូរ៉ា ពិតជាបានប្រព្រឹត្តបទល្មើស **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ពិតប្រាកដមែន ។ ដូច្នេះតំណាងអយ្យការសូមដម្កល់បទចោទនេះនៅដដែល តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ២២៤ ដកសព ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ ផ្តន្ទាទោសតាមមាត្រាតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជាមូលដ្ឋាន។

១០-តាមចម្លើយរបស់ជនជាប់ចោទ របាយការណ៍របស់មន្ត្រីយុត្តិធម៌ និងការសន្និដ្ឋានរបស់តំណាងអយ្យការ មានភាពស៊ីសង្វាក់គ្នា សបញ្ជាក់ឱ្យឃើញថា៖ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ នៅភូមិដើមគ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ឈ្មោះ [redacted] ធារ៉ា ,ឈ្មោះ [redacted] សុធី ,ឈ្មោះ [redacted] ឈុននី និងឈ្មោះ [redacted] ប៉ូរ៉ា ពិតជាបានប្រព្រឹត្តបទល្មើស **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ពិតប្រាកដមែន ។

១១-អំពើរបស់ជនជាប់ចោទ បានធ្វើឱ្យធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសង្គមបានសង្គមចាត់ទុកជាអំពើល្មើសផ្នែកព្រហ្មទណ្ឌតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១២-ជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ភេទប្រុស អាយុ ២៥ឆ្នាំ និងឈ្មោះ [redacted] សុធី ភេទប្រុស អាយុ ២០ឆ្នាំ ជានីតិជន មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយមានចេតនាពិតប្រាកដក្នុងការប្រព្រឹត្តអំពើខាងលើ។

១៣-ជនជាប់ចោទឈ្មោះ [redacted] ឈុននី ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ [redacted] ប៉ូរ៉ា ភេទប្រុស អាយុ ១៧ឆ្នាំ ជាអនីតិជនក្តី ប៉ុន្តែបុគ្គលិកលក្ខណៈរបស់គេ មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយមានចេតនាពិតប្រាកដក្នុងការប្រព្រឹត្តអំពើខាងលើ។

១៤-ជនជាប់ចោទឈ្មោះ [redacted] ឈុននី ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ [redacted] ប៉ូរ៉ា ភេទប្រុស អាយុ ១៧ឆ្នាំ ជាអនីតិជន គប្បីពិចារណាតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

១៥-មានភស្តុតាង ដាក់បន្ទុកគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ភេទប្រុស អាយុ ២៥ឆ្នាំ(ក្នុងឃុំ) ,ឈ្មោះ [redacted] **សុធី ហៅ អាញ៉ាញ់** ភេទប្រុស អាយុ ២០ឆ្នាំ(ក្នុងឃុំ) ,ឈ្មោះ [redacted] ឈុននី ភេទប្រុស អាយុ ១៧ឆ្នាំ(ក្នុងឃុំ) និងឈ្មោះ [redacted] ប៉ូរ៉ា ភេទប្រុស អាយុ ១៧ឆ្នាំ (ក្នុងឃុំ) ពីបទ៖ **រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិដើមគរ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ បញ្ញត្តិផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ខ.វត្ថុចាប់យក ៖**

- ម៉្សៅក្រាមពណ៌សថ្លា សង្ស័យជាសារធាតុញៀនមេតង់ហ្វេតាមីន(ICG) ពីរកញ្ចប់តូច ទម្ងន់ ០,១៩(សូន្យក្បៀសដប់ប្រាំបួន)ក្រាមវិចខ្ចប់ក្នុងស្រោមសំបុត្រធំ ចំនួន ០២ ពណ៌គគី គ្មានលេខកូដ គប្បីតុលាការរឹបអូសបំផ្លាញចោល។
- ខ្សៀវសំរាប់ប្រើប្រាស់ចំនួន ០១(មួយ គប្បីតុលាការរឹបអូសបំផ្លាញចោល។



Scanned with CamScanner

-ម៉ូតូចំនួន ០១(មួយ)គ្រឿង ម៉ាកគុប៥០ ស្លាកលេខ ភ្នំពេញ 1N-9329 គប្បីតុលាការប្រគល់ឱ្យម្ចាស់ដើមវិញ។

-ទូរស័ព្ទដៃចំនួន ០១(មួយ)គ្រឿង ម៉ាក Iphone 6 ពណ៌ទឹកប្រាក់ គប្បីតុលាការប្រគល់ឱ្យម្ចាស់ដើមវិញ។

**ហេតុដូច្នេះ សាលាដំបូងខេត្តកណ្ដាល វិនិច្ឆ័យសេចក្ដី**

១-ផ្ដន្ទាទោសលើជនជាប់ចោទ៖

១.១-ឈ្មោះ [redacted] ធារ៉ា ភេទប្រុស អាយុ ២៥ឆ្នាំ(មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ។

១.២-ឈ្មោះ [redacted] សុធី ភេទប្រុស អាយុ ២០ឆ្នាំ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០២(ពីរ)ឆ្នាំ។

១.៣-ឈ្មោះ [redacted] ឈុននី ភេទប្រុស អាយុ ១៧ឆ្នាំ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១(មួយ)ឆ្នាំ។

១.៤-ឈ្មោះ [redacted] បូរ៉ា ភេទប្រុស អាយុ ១៧ឆ្នាំ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១(មួយ)ឆ្នាំ។

ពីបទ៖ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិដើមគរ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ បញ្ញត្តិផ្ដន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុចាប់យក៖

២.១-ម្សៅក្រាមពណ៌សថ្លា សង្ស័យជាសារធាតុញៀនមេតង់ហ្វេតាមីន(ICG) ពីរកញ្ចប់តូច ទម្ងន់ ០,១៩(សូន្យក្បៀសដប់ប្រាំបួន)ក្រាម វិចខ្ចប់ក្នុងស្រោមសំបុត្រធំ ចំនួន ០២ ពណ៌គគី គ្មានលេខកូដ ត្រូវរឹបអូសបំផ្លាញចោល។

២.២- ខ្សៀវសំរាប់ប្រើប្រាស់ចំនួន ០១(មួយ ត្រូវរឹបអូសបំផ្លាញចោល។

២.៣-ម៉ូតូចំនួន ០១(មួយ)គ្រឿង ម៉ាកគុប៥០ ស្លាកលេខ ភ្នំពេញ 1N-9329 ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ។

២.៤-ទូរស័ព្ទដៃចំនួន ០១(មួយ)គ្រឿង ម៉ាក Iphone 6 ពណ៌ទឹកប្រាក់ ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ។

-សាលក្រមនេះជំនុំជំរះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ,ឈ្មោះ [redacted] សុធី ,ឈ្មោះ [redacted] ឈុនី និងឈ្មោះ [redacted] បូរ៉ា ។

ទុកសិទ្ធិឲ្យប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

[redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ០៩កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កណ្ដាល,ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០២២

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]